**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាអធិដ្ឋាន២៤ម៉ោងសម្រាប់ព្រះជាម្ចាស់**
**ក្រែងត្រយឹង ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៩**

# ផ្លែនៃការអធិដ្ឋានគឺសេចក្ដីសុខ

**អត្ថបទទី១៖ ហូសេ ៦,១-៦**

យើងត្រូវយកចិត្តទុកដាក់ស្គាល់ព្រះអម្ចាស់ឲ្យបានច្បាស់ ព្រះអង្គប្រាកដជាយាងមកជួយពួកយើងគឺពិតដូចថ្ងៃរះ។ ព្រះអង្គនឹងយាងមកប្រោសពួកយើង ដូចភ្លៀងធ្លាក់ស្រោចស្រពផែនដីតាមរដូវកាល”។ ហាស ៦,៣

**ដំណឹងល្អ៖ លូកា ១៨,៩-១៤**

ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ព្រះជាម្ចាស់ប្រោសអ្នកទារពន្ធនេះឲ្យបានសុចរិត ហើយគាត់ត្រឡប់ទៅផ្ទះវិញ រីឯបុរសខាងគណៈផារីស៊ីមិនបានសុចរិតទេ។ អ្នកណាលើកតម្កើងខ្លួន អ្នកនោះនឹងត្រូវគេបន្ទាបចុះ រីឯអ្នកដែលបន្ទាបខ្លួននឹងត្រូវគេលើកតម្កើងវិញ»។ លក ១៨,១៤

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ដែលយើងចាប់ផ្ដើមបើកការអធិដ្ឋាន២៤ម៉ោងសម្រាប់ព្រះជាម្ចាស់ ព្រះសហាគមន៍បង្ហាញផ្លូវមួយ ដើម្បីឲ្យយើងរៀបចំរបៀបអធិដ្ឋាន ដើម្បីឲ្យយើងរៀបចំជីវិតរបស់យើងជាគ្រីស្តបរិស័ទ ដែលបង្កើតទំនាក់ទំនងជាមួយព្រះជាម្ចាស់តាមរយៈការអធិដ្ឋាន។ ពេលយើងនឹកឃើញជីវិតរបស់ព្រះយេស៊ូ ព្រះអង្គបានណែនាំឲ្យអ្នកជំងឺជាសាស្បើយ ណែនាំឲ្យអ្នកដែលមានបាបទទួលជីវិតថ្មីដោយលើកលែងទោសឲ្យគេ។ ប៉ុន្តែ គ្រប់ពេលវេលានៅពេលព្រះយេស៊ូបានទេសនាផង ណែនាំគេផង ព្យាបាលគេផង ព្រះយេស៊ូបានយកពេលដើម្បីអធិដ្ឋាន។ ជូនកាលយើងឃើញ ព្រឹកឡើងព្រះយេស៊ូឡើងលើភ្នំដើម្បីអធិដ្ឋាន មុនព្រះយេស៊ូបួននំប៉័ងប្រាំដុំនិងត្រីពីរកន្ទុយសម្រាប់មនុស្សប្រាំពាន់នាក់បរិភោគព្រះយេស៊ូបានអធិដ្ឋាន នៅមុនព្រះយេស៊ូសោយទិវង្គត ព្រះអង្គជប់លៀងជាមួយក្រុមសាវ័កហើយព្រះអង្គទៅសួនច្បារកេតសេម៉ានីដើម្បីអធិដ្ឋាន។ គ្រប់ពេលវេលាព្រះយេស៊ូបានអធិដ្ឋាន ព្រះអង្គបានបង្កើតទំនាក់ទំនងជាមួយព្រះជាម្ចាស់តាមរយៈគ្រីស្តទូតពីដើម ព្រះយេស៊ូបានណែនាំឲ្យយើងមានសិទ្ធិអធិដ្ឋានដូចព្រះអង្គ។ ក្រុមគ្រីស្តទូតបានសួរទៅព្រះយេស៊ូថា **តើយើងធ្វើដូចម្ដេចដើម្បីអធិដ្ឋានទៅព្រះជាម្ចាស់?** ព្រះអង្គឆ្លើយថា **នៅពេលយើងចង់អធិដ្ឋានទៅព្រះជាម្ចាស់ឲ្យយើងអធិដ្ឋានដូចតទៅ ឱព្រះបិតាយើងខ្ញុំអើយ!...** នេះជាពាក្យអធិដ្ឋានរបស់យើងជារៀងរាល់ថ្ងៃ។ ព្រះយេស៊ូបានអនុញ្ញាតិឲ្យគ្រីស្តទូតនិងយើងទាំងអស់គ្នា មានសិទ្ធិអធិដ្ឋានតាមរបៀបព្រះយេស៊ូ មានន័យថាឲ្យយើងអធិដ្ឋានតាមរបៀបព្រះយេស៊ូនៅក្នុងចិត្តគំនិតរបស់យើង នៅក្នុងជីវិតរបស់យើងដែរ។ ជូនកាលក្រុមគ្រីស្តទូតគេឆ្ងល់ព្រះយេស៊ូចាត់ឲ្យគេទៅប្រកាសដំណឹងល្អ ព្រះយេស៊ូណែនាំឲ្យគេមានឫទ្ធានុភាពដើម្បីព្យាបាល

អ្នកជំងឺ ពេលគេត្រឡប់មកវិញគេប្រាប់ទៅព្រះយេស៊ូថា យើងខិតខំព្យាបាលអ្នកជំងឺ យើងខិតខំបណ្ដេញខ្មោចនិងវិញ្ញាណអាក្រក់ ប៉ុន្តែឥតមានប្រសិទ្ធិភាព ពេលនោះព្រះយេស៊ូឆ្លើយភ្លាមថា មកពីអ្នកខ្វះជំនឿ មកពីខ្វះការអធិដ្ឋាន មកពីខ្វះទំនាក់ទំនងជាមួយព្រះជាម្ចាស់។ យើងអរព្រះគុណព្រះជាម្ចាស់ ដែលបានបើកឱកាសឲ្យយើងមាន២៤ម៉ោងដើម្បីអធិដ្ឋាន ទោះបីយើងមិនអាចអធិដ្ឋានពេញតែកុំឲ្យយើងរវីរវល់នឹងការងារដែលយើងកំពុងធ្វើ ឲ្យចិត្តរបស់យើងបន្តអធិដ្ឋានរួមជាមួយគ្នាទៀត។

ការអធិដ្ឋានទៅជាពេលវេលាមួយ ដែលយើងបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះជាម្ចាស់ និងណែនាំឲ្យយើងទទួលកម្លាំង ណែនាំឲ្យយើងទទួលជំនឿ ណែនាំឲ្យយើងទទួលសមត្ថភាព ដើម្បីរស់នៅជាគ្រីស្តបរិស័ទក្នុងសង្គមបច្ចុប្បន្ននេះ។ អត្ថបទទីមួយ ផ្លូវដែលព្រះជាម្ចាស់បើកតាមរយៈព្យាការី ហូសេ "**យើងចង់ឲ្យអ្នករាល់គ្នាស្គាល់យើង យើងចង់ឲ្យអ្នករាល់គ្នាយកចិត្តទុកដាក់ស្ដាប់យើង យើងចង់ឲ្យអ្នករាល់គ្នាយកចិត្តទុកដាក់ស្គាល់ព្រះអម្ចាស់ឲ្យបានច្បាស់**" ដើម្បីស្គាល់ព្រះជាម្ចាស់ឲ្យបានច្បាស់ មានតែផ្លូវមួយគឺយកចិត្តទុកដាក់អធិដ្ឋាន ដើម្បីស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ មានតែផ្លូវមួយគឺយកចិត្តទុកដាក់អធិដ្ឋាននៅក្នុងការបង្កើតទំនាក់ទំនងនៅក្នុងរបៀបរស់នៅជាគ្រីស្តបរិស័ទប្រចាំថ្ងៃ។ ថ្ងៃនេះព្យាការី ហូសេ បានបើកផ្លូវយ៉ាងច្បាស់ឲ្យយើង គឺឲ្យយើងធ្វើដូចម្ដេចដើម្បីភ្ជាប់ជាមួយព្រះជាម្ចាស់ ឲ្យយើងមានចិត្តភក្ដីភាព ចិត្តស្មោះត្រង់ចំពោះព្រះជាម្ចាស់។ លោក ហូសេ មិនចង់ឲ្យបន្តយកជង្វាយដុត ឲ្យយើងធ្វើយញ្ញបូជា ឲ្យយើងអធិដ្ឋានតែមិននឹកឃើញអ្វីដែលយើងបានអធិដ្ឋាននោះទេ...។ ថ្ងៃនេះលោក ហូសេ រំលឹកយើងឲ្យយើងមានចិត្តគំនិតតែមួយជាមួយព្រះជាម្ចាស់ ឲ្យយើងមានចិត្តស្មោះត្រង់ ស្មោះសគ្រដើម្បីធ្វើដំណើរជាមួយព្រះជាម្ចាស់ ព្រះជាម្ចាស់ស្រឡាញ់យើងឲ្យយើងស្រឡាញ់ព្រះជាម្ចាស់។ នៅក្នុងគម្ពីរដំណឹងល្អថ្ងៃនេះយើងឃើញអំពីរបៀបដែលយើងត្រូវការអធិដ្ឋាន ពេលយើងអធិដ្ឋានមិនមែនអង្គុយនៅមុខព្រះជាម្ចាស់ហើយនិយាយអួតខ្លួន ការអធិដ្ឋានជារបៀបអ្នកមានបាបដែលនិយាយខ្លីៗថា "**ឱព្រះជាម្ចាស់អើយ! សូមអាណិតមេត្តាទូលបង្គំជាមនុស្សបាបផង**"។ យើងជាមនុស្សបែបណាព្រះជាម្ចាស់ដឹងហើយ សំខាន់ឲ្យយើងដាក់ខ្លួនដើម្បីទូលអង្វរព្រះជាម្ចាស់ដោយនឹកឃើញសូមព្រះអង្គអាណិតអាសូរទូលបង្គំ។ យើងដឹងថា យើងមិនមែនជាមនុស្សពិសេសអស្ចារ្យ ខ្ញុំខិតខំធ្វើតាមអ្វីដែលខ្ញុំអាចធ្វើបាន ខ្ញុំមានអំពើបាបខ្ញុំត្រូវតែប្រាប់ដល់ព្រះជាម្ចាស់ "**ឱព្រះជាម្ចាស់អើយ! សូមអាណិតមេត្តាទូលបង្គំជាមនុស្សបាបផង**"។

ដើម្បីត្រៀមខ្លួនធ្វើជាមនុស្សសុចរិតយ៉ាងពិតប្រាកដ គឺយើងធ្វើយ៉ាងណាដើម្បីបន្ទាបខ្លួនមិនមែនអួតខ្លួន។ ១០ថ្ងៃទៀត យើងចូលនៅក្នុងអាទិត្យពិសិដ្ឋ នៅថ្ងៃព្រហស្បតិ៍ពិសិដ្ឋដែលព្រះ

យេស៊ូលាងជើងឲ្យក្រុមសាវ័ក នេះជាពេលវេលាដែលព្រះយេស៊ូបន្ទាបខ្លួន ជាពេលវេលាដែលព្រះយេស៊ូបង្ហាញអំពីរបៀបជាក់ស្តែង យើងត្រូវការធ្វើដូចម្តេចដើម្បីដាក់ខ្លួនបន្ទាបខ្លួនដោយយើងធ្វើជាអ្នកបម្រើ។ ការអធិដ្ឋាន ណែនាំឲ្យយើងចេះបម្រើ ណែនាំឲ្យយើងសម្តែងធម៌មេត្តាករុណា នៅពេលនោះយើងដឹងថានៅក្នុងពិភពលោករបស់យើងមានសេចក្តីសុខសាន្ត។ អ្នកម្តាយតេរេសា ធ្លាប់និយាយច្រើនដង **"អធិដ្ឋានដើម្បីសុំជំនឿ នៅពេលយើងមានជំនឿយើងបម្រើ នៅពេលយើងបម្រើយើងបង្ហាញសេចក្តីស្រឡាញ់ នៅពេលយើងបង្ហាញសេចក្តីស្រឡាញ់យើងកសាងសុខសន្តិភាព"**។

ថ្ងៃនេះដែលយើងមានពេលវេលា២៤ម៉ោង ជាពេលវេលាដើម្បីអធិដ្ឋានស្គាល់ព្រះជាម្ចាស់ថែមទៀត ជាពេលវេលាដើម្បីអធិដ្ឋានលះបង់ចោល ដាក់ខ្លួន បន្ទាបខ្លួន ដើម្បីមានចិត្តគំនិតតែមួយជាមួយព្រះជាម្ចាស់។ អធិដ្ឋាន ដើម្បីបង្ហាញអំពីចិត្តស្មោះដែលយើងមានចំពោះព្រះជាម្ចាស់ អធិដ្ឋានដើម្បីឲ្យយើងមានជំនឿថែមទៀត ដើម្បីឲ្យយើងចេះបម្រើ ដើម្បីឲ្យយើងចេះស្រឡាញ់ថែមទៀត នោះណែនាំឲ្យពិភពលោករបស់យើងអាចមានសេចក្តីសុខ។ គោលដៅរបស់យើង គឺធ្វើយ៉ាងណាឲ្យពិភពលោករបស់យើងរកឃើញសុភមង្គល គឺសេចក្តីសុខសម្រាប់គ្រួសារយើង សម្រាប់ប្រទេសយើង សម្រាប់ពិភពលោកយើង ដែលកំពុងជាប់ជាមួយសង្គ្រាម ជាមួយគ្រោះទុរភិក្ស ជាមួយអំពើហិង្សា...។ នៅក្នុងការអធិដ្ឋាន២៤ម៉ោងរបស់យើង យើងអធិដ្ឋានសម្រាប់យើង សម្រាប់ព្រះសហគមន៍យើង សម្រាប់ប្រទេសយើង ឲ្យយើងមានគំនិតថែមទៀតឲ្យយើងអធិដ្ឋានសម្រាប់ពិភពលោកដែរ។ សព្វថ្ងៃ នៅក្នុងពិភពលោកយើងមានបញ្ហាច្រើន ដូច្នេះយើងត្រូវការអធិដ្ឋានច្រើនទៀត ដើម្បីឲ្យសេចក្តីសុខមានថ្ងៃណាមួយនឹងមកដល់។ ការអធិដ្ឋានរបស់យើង កុំឲ្យជាពាក្យអធិដ្ឋានដូចទឹកសន្សើមពេលព្រឹកដែលមានមួយរយៈពេលខ្លី ពេលមានព្រះអាទិត្យមកដល់ធ្វើឲ្យវាបាត់អស់ហើយ។ ដូច្នេះឲ្យការអធិដ្ឋានរបស់យើង ទៅជាការអធិដ្ឋានដែលចូលយ៉ាងជ្រៅនៅក្នុងដួងចិត្តរបស់យើង នៅក្នុងពិភពលោករបស់យើងដើម្បីឲ្យយើងឃើញផ្លែដែលសំខាន់បំផុត គឺសេចក្តីសុខនៅក្នុងចិត្ត និងសេចក្តីសុខនៅក្នុងពិភពលោករបស់យើង។

ថ្ងៃនេះយើងអរព្រះគុណព្រះជាម្ចាស់ ដែលបើកពេលវេលាដើម្បីយើងអធិដ្ឋានរួមគ្នា២៤ម៉ោង ដើម្បីកសាងពិភពថ្មី ដោយដឹងថាមានតែព្រះជាម្ចាស់ដែលអាចសង្គ្រោះយើង មានតែព្រះជាម្ចាស់ដែលអាចប្រទានជីវិតឲ្យយើងអស់កល្បជានិច្ច។ អាម៉ែន៕